**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ** ៦៥៦/០៨ **គ.ជ.ប**

# សេចក្តីរំលឹក
## ស្តីពី
## បទប្បញ្ញត្តិមួយចំនួនសម្រាប់ការឃោសនាបោះឆ្នោត

-អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បទបញ្ជា នីតិវិធីរបស់ គ.ជ.ប និងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ ។

-ដើម្បីឱ្យដំណើរការនៃការឃោសនាបោះឆ្នោតប្រព្រឹត្តទៅប្រកបដោយសន្តិសុខ សណ្តាប់ធ្នាប់ សេរី ត្រឹមត្រូវ យុត្តិធម៌ គ្មានការគំរាមកំហែង គ្មានការបំភិតបំភ័យ គ្មានអំពើហិង្សា ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមធ្វើការរំលឹក ដល់គ្រប់គណបក្សនយោបាយ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ ដែលទទួលស្គាល់ដោយ គ.ជ.ប រួចហើយ នូវបទប្បញ្ញត្តិមួយចំនួនដូចខាងក្រោម ។

១-គណបក្សនយោបាយ និងបេក្ខជនទាំងអស់ត្រូវជៀសវាងប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋ ទៅលើគណបក្សនយោបាយ ឬបេក្ខជនដទៃ ។ គ្រប់គណបក្សនយោបាយ និងបេក្ខជនទាំងអស់មិនត្រូវញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភ គំរាមកំហែង អំពើហិង្សា ឬបំភិតបំភ័យទៅលើបុគ្គល ឬគណបក្សនយោបាយដទៃឡើយ ។

២-ក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត គណបក្សនយោបាយទាំងអស់ បេក្ខជនទាំងអស់ សមាជិកនៃគណបក្សនយោបាយទាំងអស់ អ្នកគាំទ្រទាំងអស់ ត្រូវគោរពតាមវិធាន បទប្បញ្ញត្តិ និងគោលការណ៍ ដែលចែងក្នុងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បទបញ្ជា នីតិវិធីរបស់ គ.ជ.ប និងក្រមសីលធម៌ គោរពតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

៣-មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងមន្ត្រីតុលាការ មិនត្រូវប្រើឥទ្ធិពលអំណាចនៃតួនាទីរបស់ខ្លួន ដោយប្រយោល

ឬចំពោះទៅលើដំណើរការបោះឆ្នោត ដូចជាការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬប៉ុនប៉ងបំផ្លិចបំផ្លាញ ធ្វើឱ្យខូចទ្រព្យសម្បត្តិ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យ ឬប្រើប្រាស់អគារការិយាល័យរបស់រដ្ឋ ដើម្បីឃោសនាបោះឆ្នោតស្វែងរកសំឡេងឆ្នោត ឬចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោត សម្រាប់គណបក្សនយោបាយណាឡើយ ។

៤-បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងធ្វើការ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងមន្ត្រីតុលាការ អាចចូលរួម ក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់បាន ប៉ុន្តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន និងមិនត្រូវមានអាវុធជាប់នឹងខ្លួនឡើយ ។

៥-គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ មិនត្រូវប្រើប្រាស់មធ្យោបាយដឹកជញ្ជូន ដែលជាសម្បត្តិរបស់រដ្ឋដូចជា រថយន្ត ទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទ ដែលប្រើប្រាស់ស្លាកសញ្ញារាជការ ឬរដ្ឋ ន.ប ខ.ម និងរាជរដ្ឋាភិបាល ដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោតឱ្យគណបក្សណាមួយ ឬបេក្ខជនណាម្នាក់ និងដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ។

៦-គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ និងអ្នកគាំទ្រទាំងអស់ មិនត្រូវប្រើប្រាស់តួនាទី សិទ្ធិអំណាច បុព្វសិទ្ធិ ឥទ្ធិពល ឬសិទ្ធិអំណាចខាងមេបាខាងមេគ្រួសារ ខាងអាពាហ៍ពិពាហ៍ ខាងសាសនា និងខាងប្រពៃណីទំនៀមទំលាប់ ដើម្បីបង្ខំ ឬគំរាមកំហែងក្នុងគោលបំណងទទួលបានការគាំទ្រ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សង្ឃឹមយ៉ាងមុតមាំថា គ្រប់គណបក្សនយោបាយ បេក្ខជន និងអ្នកគាំទ្រទាំងអស់ នឹងអនុវត្តតាមខ្លឹមសារនៃសេចក្តីរំលឹកនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៨

**ត.ប គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**អគ្គលេខាធិការ**

ទេព នីថា

**ចម្លងជូន :**

- ក្រសួងមហាផ្ទៃ
- គ្រប់គណបក្សនយោបាយដែលបានឈ្មោះបោះឆ្នោត
- គ្រប់សាលាខេត្ត ក្រុង
- គ្រប់ គខ/គប
- អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ
- គ្រប់ គឃ/សប
- ឯកសារ កាលប្បវត្តិ